**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩**
ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់
ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩

# សេចក្តីជូនដំណឹង

ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីបន្តចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានទាន់ពេលវេលា និងបង្កើតបានភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយទប់ទល់នឹងជំងឺរាតត្បាតសកល កូវីដ-១៩ កន្លងមកក្រុមការងារបាននាំចូលឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) MOLNATRIS (Molnupiravir Capsules 200mg) ចែកចាយបន្តក្នុងតម្លៃ ៥៥ ដុល្លារអាម៉េរិក ក្នុង១ដូស សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ចាប់ពីកម្រិតស្រាលទៅមធ្យម ចំពោះមនុស្សពេញវ័យ។ ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការឱសថនេះ និងចូលរួមលើកកម្ពស់សុខុមាលភាពនិងជីវភាពប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានផ្តល់ថវិកាឧបត្ថម្ភ ដូចនេះ ក្រុមការងារនឹងចែកចាយឱសថ ម៉ូលណាទ្រីស ក្នុងតម្លៃ **៥០ ដុល្លារ អាម៉េរិក** ក្នុង១ដូស ចាប់ពីថ្ងៃចន្ទ ទី១៤ ខែមីនា ឆ្នាំ២០២២ នេះតទៅ ជូនមន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន តាមលក្ខខណ្ឌដូចខាងក្រោម៖

- បុគ្គលម្នាក់ មានសិទ្ធិបញ្ជាទិញពី១ ដល់១០ដូស
- មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន និងឱសថស្ថានរង មានសិទ្ធិបញ្ជាទិញពី១០ ដល់១០០ដូស (ត្រូវមានលិខិតអនុញ្ញាតបើកអាជីវកម្ម) ហើយអាចលក់បន្តមិនលើសពី ៦០ ដុល្លារអាម៉េរិក ក្នុង១ដូស
- មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន អាចបញ្ជាទិញសារជាថ្មី យ៉ាងតិច ១សប្តាហ៍ក្រោយបញ្ជាទិញលើកចុងក្រោយ។

**បញ្ជាក់៖** ករណីមន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ឬអ្នកលក់ យកទៅលក់បន្តលើសពីតម្លៃកំណត់ខាងលើ ក្រុមការងារនឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការ តាមនីតិវិធីជាធរមាន។

ដូចនេះ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន អាចបញ្ជាទិញឱសថម៉ូលណាទ្រីស (Molnupiravir Capsules 200mg) **ដោយផ្ទាល់នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសាខាប្រៃសណីយ៍កម្ពុជាខេត្ត។** សម្រាប់ការផ្តល់មតិត្រលប់អំពីការផ្តល់សេវា ឬព័ត៌មានបន្ថែម សូមទាក់ទងទូរសព្ទលេខ ១២៣/ ០៧៧ ៨៦៧ ៩៥៧/០៩៦ ៤៦៦ ៤៦៤៦ ជារៀងរាល់ម៉ោងធ្វើការ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

# ព័ត៌មានសង្ខេបអំពីឱសថម៉ូលណាទ្រីស

## ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម

ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ បាននាំចូលឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ដែលមានព័ត៌មានសង្ខេបដូចខាងក្រោម

- បរិមាណ ១ដប មាន ៤០គ្រាប់
- តម្លៃ ៥០ ដុល្លារ ក្នុង១ដប
- ការប្រើប្រាស់
  - -សម្រាប់ព្យាបាលជំងឺកូវីដ ១៩ ចាប់ពីកម្រិតស្រាលទៅមធ្យម ចំពោះមនុស្សពេញវ័យ អាយុចាប់ពី ១៨ ឆ្នាំឡើង
  - -លេបក្រោយទទួលទានអាហាររួច ឬពេលពោះទទេ និងគួរលេបទាំងមូលជាមួយទឹកមួយកែវ ដោយមិនត្រូវបើកគ្រាប់ កិនបំបែក ឬទំពារទេ
  - -លេបម្តង ៤ គ្រាប់ (ក្នុង ១គ្រាប់មានកម្រិត ២០០ មីលីក្រាម)
  - -លេប ១ ថ្ងៃ ២ ដង (រៀងរាល់ ១២ ម៉ោងម្តង សម្រាប់រយៈពេល ៥ ថ្ងៃ)
  - -សូមពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬឱសថការីមុនពេលប្រើឱសថម៉ូលនូពីរ៉ាវា
- សូមរក្សាឱសថនេះនៅក្នុងកំប៉ុងដើមបិទជិត នៅទីកន្លែងស្ងួត មានសីតុណ្ហភាពមិនលើស ៣០ អង្សាសេ




សម្រាប់ព័ត៌មានបន្ថែម សូមអានសេចក្តីណែនាំទូទៅស្តីពីការប្រើប្រាស់ឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) តាម QR Code

## បុគ្គលម្នាក់ស្នើសុំទិញ ពី ១ ប្រអប់ ដល់ ១០ ប្រអប់
## ឱសថស្ថានអាចស្នើសុំទិញ ពី ១០ ប្រអប់ ដល់ ១០០ ប្រអប់

- សូមភ្ជាប់អត្តសញ្ញាណបណ្ណផ្ទាល់ខ្លួន
- សូមភ្ជាប់លិខិតអនុញ្ញាតបើកអាជីវកម្ម (សម្រាប់មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង)
- តម្លៃ ៥០ ដុល្លារ ក្នុង ១ ប្រអប់។ សូមទូទាត់ប្រាក់តាមរយៈធនាគារ ABA ឬ ធនាគារកាណាឌីយ៉ា ដោយផ្ទាល់នៅបញ្ជរ
- បញ្ជាក់ ៖ អាចបញ្ជាទិញសារជាថ្មី យ៉ាងតិច ៧ថ្ងៃ ក្រោយបញ្ជាទិញលើកចុងក្រោយ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងទូរសព្ទ ដូចខាងក្រោម៖

Hotline 123
077 867 957
096 466 4646

រៀងរាល់ថ្ងៃចន្ទ - សុក្រ
ពេលព្រឹក ម៉ោង ៨-១២
ពេលរសៀល ម៉ោង ២-៥

v4. ១១ មីនា ២០២២